# ជំពូកទី១

## Zenai da

## គេចពីចចកចូលរូងខ្លា

ការភ័យខ្លាចមិនដែលមាននៅក្នុងវចនានុក្រមរបស់ហ្សេន Zenaida ដូចពេលនេះទេ។ ក្នុងនាមអ្នកសរសេរកាសែតអនឡាញ ហ្សេនជាស្ត្រីវ័យក្មេងដែលក្លាហានជាងគេ ហើយក្នុងចំណោមកម្មសិក្សាការីនាទីក្រុង New Jersey នាងបានចេញអត្ថបទច្រើនបំផុតអំពីរឿងរបស់ពួកប្រព្រឹត្តអំពើបៀតបៀននារី និងក្មេងសាសន៍ផ្សេងនៅអាមេរិក។

....ប៉ុន្តែពេលនេះ នាងគ្មានផ្លូវដែលនាងនៅថតបន្តបានឡើយ។ ក្លិនឈាមបានព្រមានបេះដូងនាង ហើយអ្វីដែលនាងឃើញ បានកន្ត្រាក់រាងកាយនាងមិនឱ្យឃ្លីកបន្ថែមបានសូម្បីតែកន្លះឃ្លីកទៀតក្តី។

«រត់! ហ្សេនរត់!»

គតិបង្ខំនាងឱ្យដកខ្លួនជាប្រញាប់។ នេះគឺជាផ្លូវល្បីមួយនៅ Paterson ទីដែលឧក្រិដ្ឋកម្មកើតឡើងលំដាប់លេខបីនៅអាមេរិក។ និពន្ធនាយកបានព្រមាននាងរួចហើយ នាងក៏បានគិតថានឹងបោះបង់ចោលគំនិតមកកាន់តំបន់នេះដែរ តែល្ងាចមិញពេលចេញពីសម្ភាសន៍ប្រធានផ្នែកអចលនទ្រព្យម្នាក់ នាងចៃដន្យចេញពីបន្ទប់ទឹកស្រី បានប្រទះឃើញនាយកផ្នែកម្នាក់នៃធនាគារ Synchrony Bank ត្រូវជនមិនស្គាល់មុខបីនាក់ភ្ជង់និងរុញបញ្ចូលឡាន។ ដោយមានចង្កូតឡាននៅនឹងដៃស្រាប់ នាងមិនអាចធ្វើមិនឃើញទេ ក្រោយបានប្ដឹង នាងបានប្រដេញតាមភ្លាមៗ។

ហ្សេនជាកូនបារាំងកាត់ជប៉ុន។ ប៉ានាងជាក្មេងកំព្រានិងធំមកសមាជិកម្នាក់នៃក្រុមម៉ាហ្វៀត្រកូលធំមួយនៅជប៉ុន ហើយបានប្តូរមកនៅញូសេស៊ី រីឯម្តាយនាងជាអ្នកច្នៃម៉ូតសញ្ជាតិអាមេរិកដើមកំណើតបារាំង។

តាំងពីម្តាយរបស់នាងបានស្លាប់អស់រយៈពេលជាង៥ឆ្នាំមក ឯប៉ារបស់នាងបន្តបាត់ខ្លួន នាងបានជាប់គាំងនៅជំងឺស្ពឹកស្លុយ ដែលទាមទាររុករកឧក្រិដ្ឋជនដែលចាប់ប៉ានាងទៅ។

ហ្សេនបកក្រោយរត់ចុះមកក្រោមនៃតំបន់ជម្រាលស្ងាត់ សីតុណ្ហភាពស្ទើរតែធ្លាក់ចុះក្នុងល្បឿនលឿនពី១៨មកដល់៣ដឺក្រេ។

អាវគ្របក្រៅនេះ ធ្វើឱ្យហ្សេនរត់ចេញរឹតតែយឺតឡើងៗ។

កណ្ដាលផ្លូវបេតុងត្រជាក់មានតែខ្យល់ដកដង្ហើមដែលចេញមកសឹងកកទាំងផ្សែង តំបន់នេះជាវីឡាធំៗនិងឃ្លាំងស្ងាត់ វាមិនងាយមានគេឆ្លងកាត់ដូចទីក្រុងឡើយ។

គ្មានផ្សែងរថយន្តពុលឬក្លិនស្អុយនៃកាកសំណល់មនុស្ស មានតែស្នូរដែលប្រដេញមក។ ស្នូរជើងឱបៗប្រញាប់និងធ្ងន់ មិនមែនមនុស្សម្នាក់ឬពីរទេ អាចច្រើន។

ហ្សេនមិនគិតថានាងត្រូវស្លាប់ដូចបុរសធនាគារដែលនាងបានឃើញទេ។ នាងមិនដឹងឡើយថានាងបិទភ្នែកជិតរបៀបណាបើមិនបានសារភាពជាមួយមនុស្សសំខាន់ម្នាក់ និងរកឃើញដំណឹងប៉ានាង។

អស់រយៈពេល៥ឆ្នាំ នាងមិនដែលគិតថាខ្លួនឯងមានជីវិតទេ ដូច្នេះហ្សេនមិនខ្លាចក្ដីស្លាប់ តែនាងខ្លាចការបិទភ្នែកមិនអស់ចិត្ត។

«វានៅខាងនុះ!»

សំលេងរដឺន អាចជាម៉ាហ្វៀបារាំង ហ្សេនស្ដាប់ដឹងព្រោះនាងចេះបារាំង ជប៉ុន និងអង់គ្លេសស្ទាត់។ នាងងាកពួន។ មិនយូរទេពួកគេនឹងរកនាងឃើញ ហើយ.....នាងនឹងក្លាយជា...ផេះ។

«មនុស្សស្រី!!! សក់រួញវែងពណ៌ត្នោត អាវស្បែកវែង! ខ្មៅ! ដៃកាន់កាមេរ៉ា!»

ពួកគេនិយាយវិទ្យុទាក់ទងពីចម្ងាយ តែនាងនៅទីនេះ ក៏អាចស្ដាប់ឮបានយ៉ាងច្បាស់ព្រោះកណ្ដាលភាពត្រជាក់និងស្ងាត់ដូចរហោដ្ឋាន។ ហ្សេនលឹបពួន តែការណ៍នេះនឹងមិនបានយូរទេនាងដឹងច្បាស់ណាស់។

រកមធ្យោបាយ!!!

នាងក្រឡេកមើលទ្វារដែកពណ៌ស្លាន់មានក្បាច់អ៊ីតាលី។

នៅមិនឆ្ងាយទេ។ ផ្ទះនេះមើលទៅធំ ចោមព័ទ្ធដោយដើមឈើស៊ុបទ្រុប។ គិតថា នាងត្រូវផ្សងព្រហ្មលិខិត! ប្រសិនទ្វារស្ពាន់មិនបានចាក់សោ ហ្សេនណែដានឹងអាចចូលទៅរកម្ចាស់ផ្ទះ សុំគេជួយពន្យារពេលទម្រាំប៉ូលិសមកដល់។

ហ្សេនចោលភ្នែកសម្លឹងចុះឡើង ហើយវិភាគប៉ាន់ប្រមាណថេរវេលាដែលជើងទាំងពីរអាចនឹងរត់ទៅដល់នោះ។ ស្រីស្អាតច្រមុះស្រួចដឹងថា នាងអស់ពេលហើយ!! មច្ចុរាជនៅកៀកណាស់។

ហ្សេនណៃដាគិតថា ពីនេះទៅទ្វារ នាងអាចទៅដល់មុនពួកនោះមែន តែបើទ្វារជាប់សោ....នាងនឹងស្លាប់។ ទោះយ៉ាងណា រវាងការស្លាប់ពីរដែលមួយអាចផ្សងបាន មួយទៀតនៅចាំស្លាប់ នាងមិនគួរសំងំរង់ចាំស្លាប់ទេ

ត្រូវប្រថុយ!!!

នាងក្តាប់ដៃ រត់តម្រង់គោលដៅ

អូ! ព្រះជួយ!

ទ្វាររុញចូលបានពិតមែន!

ហ្សេនជឿថា នរណាម្នាក់នឹងជួយសង្គ្រោះនាង។ នារីរត់តាមរបៀងសួនចំហៀងស្តាំផ្ទះ នាងប្រទះឃើញជណ្តើរចុះក្រោម។ ស្នូរទឹកខ្លូកខ្លាក។

អ្នកណាម្នាក់ហែលទឹក ខាងក្រោមដីនោះជាអាងទឹក? លែងគិតច្រើនហើយ ព្រោះសំឡេងលាន់មករន្ថើន។

វាចូលទ្វារនោះហើយ!!!

ហ្សេនរត់ឆ្ពោះទៅក្រោម រហូតដល់អាងខៀវស្រងាត់ ចោលភាពផ្លេកៗក្រោមអំពូលភ្លើងរំយោល។ ជាមួយសំឡេងញ័រៗនាងស្រែកសុំ៖

«...ជួយខ្ញុំផង!!!»

មនុស្សប្រុសម្នាក់កំពុងហែលយឺតៗ។ នាងឃើញតែខ្នងដែលធំ....ហើយកំភួនដៃវែងៗ....

«ហេឡូ! ជួយៗខ្ញុំផង ពួក.....Bonannoតាមចាប់ខ្ញុំ.....»

បុរសនោះឈប់ហែលហើយសន្សឹមៗគេងាកមក។ នាងឃើញតែច្រមុះស្រួច មាត់ក្រហមទទឹកនិងពុកចង្ការីមៗ។

ខណៈគេអែបមកកៀនអាងនាងបន្តសុំ៖

«ពួក Bonanno នៅក្រៅ! ជួយខ្ញុំផងណា! »

នេះពិតជាអ្វីដែលនាងកំពុងសង្ឃឹម? ប្រសិនបើមាននរណាម្នាក់នៅក្នុងទីក្រុងនេះ ហ៊ានលាក់នាង ឬស៊ូជាមួយពួកត្រកូល Bonanno ប្រហែលជានាងយល់សប្តិចុះ។ ចំណែកមួយវិញទៀត នៅ

តំបន់នេះម្ដេចនាងហ៊ានសង្ឃឹមថា មនុស្សក្នុងអាងទឹកមិនមែនជាអ្នកជិតខាងដែលស្និទ្ធនឹងគ្រួសារម៉ាហ្វៀ Bonanno។ ពិតជាល្ងង់ដល់កម្រិត!!!

«ជួយយ៉ាងម៉េច?»

សំឡេងសួរបកមកនេះបានបណ្ដាលឱ្យនាងភាំង។ ទីនេះ មានបុរសតែម្នាក់គត់ដែលនាងកំពុងរំខានគេពីការហិចហៃល។ បុរស២នាក់ផ្សេងទៀត ដែលជាអ្នកយាមកាមបានបង្ហាញខ្លួនជុំវិញអាង និងម្នាក់ទៀតរត់ចូលមកដល់។ ហ្សេនណៃជានាងនៅតែភាំងមិនរវល់ចំពោះអ្នករាល់គ្នាទេ ភ្នែកនាងផ្ដោតលើបុរសក្នុងអាងមិនព្រិច។

«Cold!!! ពួកនៅខាងលិច មកដល់ទ្វារក្រៅ!!! គេចង់សុំចូល!»

Cold....Cold Cortes មែនទេ? នាងគិតជាមួយបេះដូងគាំងៗ ចង់តែដាច់ដង្ហើមដែលហត់។

ហ្សេនណៃជាផ្អឹងពេលមនុស្សប្រុសយោងខ្លួនឡើងមកពីក្នុងទឹក។ នាងផ្ដោតលើពាក្យ Cold or Die ដៅតូចនិងច្បាស់លើសាច់ដុំដើមដៃស្ដាំរបស់គេ។

កូនចៅគេនៅចាំស្ដាប់ហាក់ត្រហេបត្រហប ឯមនុស្សនេះនៅតែមានភាពស្ងប់។ ពេលគេឡើងមកមួយរយភាគរយ ហ្សេនងាកមុខចេញភ្លាម។

មួយខ្សែភ្នែកចុងក្រោយ នាងឃើញខ្លួនគេ.....ខ្ពស់ រឹងមាំ ហើយ.....អាក្រាត។ ប្អូនរបស់គេចង្អុលព្រហើននិងគឃ្លើនមកមុខ។ ចង្កូរពោះរបស់គេ លម្អដោយបណ្ដារោមល្អិតស្ដើងដុះជាជួរ អមរឹមៗពេញក្បាលពោះ ចង្កេះកោងណៃន។

«មិនដែលឃើញប្រុសស្រាតទេ?»

ភាសាបារាំង....គេនិយាយបានល្អណាស់។ ដូចកាលពីមុន«ស្រលាញ់គ្នាបានទេ?»....៥ឆ្នាំមុន នាងងាកមុខចេញ ខណៈមនុស្សមួយចំនួនរត់ចូលមក។

Cold Cortes អាយុ២៤ឆ្នាំ មានមុខចាស់ ស្ងួត និងត្រជាក់ដូចជនពាលអាយុ៣៥ឆ្នាំ។ គេចេញពីពន្ធនាគារមកហើយ? គ្មានអ្នកណាប្រាប់នាងទេ។ នាងគិតថា គេនៅក្នុងនោះយូរជាងនេះទម្រាំ.....នាងស្វែងរកការពិតឃើញ។

ពេលនេះ....

គេទទួលអាវកន្សែងពីកូនចៅគេ ហើយរុំ។ ភាពខ្លាំងក្នុងភ្នែកគេបានសម្លក់នាងមួយក្រឡេក រួចដៀងមកមនុស្ស៥នាក់ដែលមានកាំភ្លើងគ្រប់ដៃ។

«នាំគ្នាមកអ៊ូអរធ្វើអីនៅផ្ទះនេះ?» គេវាចាតិចៗដោយឈ្ងោកចងខ្សែចង្កេះពណ៌ស។

«យើងសុំយកស្រីនេះត្រលប់ទៅវិញ!»

ដៃនាងញ័រជាមួយម៉ាស៊ីនថត ខណៈនាងមើលម្ចាស់ផ្ទះ ហើយម្ចាស់ផ្ទះដ៏តោះតើយទម្លាក់ភ្នែកមកសម្លឹងកាមេរ៉ាក្នុងដៃនាង។

«Cold នាងជាសត្រូវពួកយើង! បងម៉ារីអូ កំពុងរង់ចាំពួកយើងចាប់អ្នកទោស!»

យើងនេះឬជាអ្នកទោសពួកវា? ព្រោះយើងឃើញរឿងរ៉ាវវាសម្លាប់មនុស្ស?

នាងគិតច្រើនណាស់ តែហ្សេនមិននិយាយចេញមួយម៉ាត់ទេ។ ភ្នែករបស់ហ្សេនណៃដា សម្លឹងប្រតិកម្មម្ចាស់ផ្ទះដូចចង់អង្វរ.....ដូចចង់ពន្យល់....តែ....នាងកំពុងហាស្លាក់!

គេងើបភ្នែកចេញពីកាមេរ៉ាសម្លឹងហ្សេន។ មនុស្សស្រីតែម្នាក់នៅចំកណ្តាលរង្វង់ក្រុមចចក និង....ទីនេះរូងខ្លា។ វាមិនដូចនាងពីមុនទេ នៅសាលា ហ្សេនណៃដាតែងតែក្តិចវាយ ឬប្រដេញដេរដាក់បណ្តាសារអ្នកណាម្នាក់ដែលហ៊ានប៊ូលីធ្វើបាបនាង។ នាងនិងគេធ្លាប់បានឈ្លោះប្រកែកគ្នាតាំងពីក្មេងៗរហូតមក ហើយធំមកដល់វ័យជំទង់ក៏.....ស្រលាញ់គ្នា។

«នាងថតការងារពួកខ្ញុំ!»

ម្នាក់ក្នុងចំណោមអ្នកប្រដេញនិយាយដោយប្រញាប់ និងឈានចូលមកបន្តិចទៀត តែក៏ត្រូវកងការពារអាងទឹកពាំងផ្លូវជាប់។

ហ្សេនណៃដា ញ័រពីលើដល់ក្រោមពេលដៃប្រុសម្ចាស់ផ្ទះលាទៅរកនាង ទារយកកាមេរ៉ា។ ហ្សេនគ្រវីក្បាល។ របស់នេះជាព័ស្តុតាងនិងជាយុត្តិធម៌សម្រាប់គ្រួសារអ្នករងគ្រោះ នាងគិតថាក្រៅពីប៉ូលិសគ្មានអ្នកណាមានសិទ្ធិយកទេ។

សូម្បី.....អតីតសង្សារនាង....Cold Cortes។

គេញញឹមបន្តិចបំបាត់ភាពខកចិត្តដែលនាងមិនបានធ្វើតាមបញ្ជា។ ពេលColdឈានជើងចូលមក ហ្សេនចង់ដកថយ តែ....ក្រោយខ្នងមានពួកBonanno នាងក៏គ្មានកន្លែងដកខ្លួនបាន។

ដៃគេធំ ក្ដោបមកលើដៃនាង។ ហ្សេនក្រាញបន្តិច តែគេជ្រួញចិញ្ចើមហើយដណ្ដើមយកបាន។ គេក្រឡេកនាងមួយឆ្វាច់ រួចទើបឈ្ងោកសម្លឹងអេក្រង់ ដៃគេចុចពិនិត្យ។

នាងផ្ទៃមមាត់ដោយការភ័យនិងទាល់ច្រក ភ្នែកទាំងគូរកំពុងរកដំណោះស្រាយ។ ភ្នែកនាងនៅផ្ចិតស្ចិតនឹងទឹកមុខCold Cortes ដែលមាំឡើងនិងរឹតតែប្ដូរមាំថែមឡើងទៀត ក្រោយសម្លឹងអ្វីដែលនាងថតបាន។

«គេ....សម្លាប់.....មនុស្ស!»

នាងប្រាប់ញ័រៗធ្វើឱ្យដង្ហើមធំបង្ហើបចេញពីទ្រូងCold។ គេងើបមុខសម្លឹងនាង ទាំងកាមេរ៉ាក្នុងដៃគេ។ សំឡេងគេស្រាលតែច្បាស់៖

«ហើយរឿងរបស់យើង?»

នាងមិនតមាត់បានទេ ជាមួយកែវភ្នែកស្អប់និងក្នាញ់ដែលគេបញ្ចេញមក។ សំណួរគេ នាងរឹតគ្មានពាក្យឆ្លើយ។

«ឈឺឆ្អាលម្ល៉េះ Zenaida Nakamura?»

បុរសស៊ិចស៊ីសួរទៀតហើយហៅនាងពេលនេះ ទាំងឈ្មោះទាំងត្រកូល។ គេគ្មានថ្ងៃភ្លេចនាងហើយគ្មានថ្ងៃ«មិនស្អប់នាង»ដូចនាងធ្លាប់សង្ឃឹមនោះដែរ។

គេហុចកាមេរ៉ាទៅពួកនោះ។ នាងចង់តវ៉ាចង់ស្ទុះមក តែគេងាកមកព្រមានហ្សេនដោយក្ដាប់មាត់ ភ្នែកគេបញ្ចេញពន្លឺកំណាច។ ពេលនេះហ្សេនស្ងៀមវិញ គេងាកទៅរកអ្នកដែលមកទទួលកាមេរ៉ាហើយបញ្ជា៖

«លុបចោលទៅ ហើយឱ្យម៉ាស៊ីនមកវិញ!»

ពួកនោះសម្លឹងកាមេរ៉ា ម្នាក់ងើបមុខមកតវ៉ា៖

«ខ្លាចតែវាផ្ញើចេញហើយទេ!»

«មិនទាន់ទេ!» Coldបញ្ជាក់។

គេត្រូវតែជឿ។ Cold Cortes ជាអ្នកជំនាញខាងបណ្ដាញអ៊ីនធឺណិត ដូច្នេះពេលពិនិត្យគេឃើញហើយថាគ្មានសញ្ញាផ្ញើចេញ។ ពួកអ្នកប្រដេញទីទើរ ខណៈColdឆក់យកម៉ាស៊ីនមកវិញហើយចុចFormatចោល។

«រួចរាល់!!! ប្រាប់ម៉ារីអូ ថាគ្មានរូបថតលើផែនដីនេះទៀតទេ!»

នាងធ្លាក់ទឹកចិត្តនិងមានភ្នែករលោងខឹង។ នាងមិនសុខចិត្តតែនាងធ្វើអ្វីមិនកើត។ ស្រីឆ្នាសរឹងរូសនេះ Coldដឹងថាមានអ្វីត្រូវជូនដល់នាងបន្តិចទៀតមិនខាន។ គេហុចកាមេរ៉ាទៅឱ្យកូនចៅកាន់ ហើយងាកមកសម្លឹងនាង។

មានស្នាមប្រឡាក់ទឹកភ្នែកចេញពីភ្នែករបស់នាងដែលនាងរឹងរូចមិនជូតឬលុប។ មានអារម្មណ៍ថាសប្បាយចិត្តឃើញនាងខឹង។

ពីមុនមក កូនកាត់បារាំងមិនដែលយំទេ ពេលនេះមិនត្រឹមតែចរិតនាងលែងកញ្ជ្រោល តែនាងក៏បានផ្លាស់ប្តូរ។ សក់របស់នាងវែងជាងមុន។ កាលនៅរៀនវិទ្យាល័យ នាងតែងតែកាត់ទុកត្រឹមស្មាជាស្ទីលក្មេងស្រីជប៉ុនរបស់នាង។ ពេលនេះសក់ពណ៌ទង់ដែងវែងនិងរលោង នឹងក្លាយជាគ្រឿងលេងសើចគួរឱ្យទាក់ចិត្តមួយសម្រាប់Cold។

ក្នុងអាវរងារខ្មៅនិងក្រាស់ Coldមិនអាចមើលរាងកាយរបស់នាងបានច្បាស់ល្អដូចក្តីនឹករឭកទេ ប៉ុន្តែគេនៅតែចាប់សង្កេតបាននូវភាពពើងកោងគ្រលួចលើទ្រូងរបស់នាង។

សុដន់របស់នាងនៅតែស្អាតហើយធំដូចជា ហ្សេនណៃជាពី៥ឆ្នាំមុន។ ការប្រឈមមុខនឹងអតីតកាលរបស់គេជាមួយនាង នឹងមិនងាយស្រួលដោះស្រាយគ្នាទេ តែយ៉ាងហោចណាស់....ពេលនេះ ព្រះបញ្ជូននាងមកឱ្យគេវិញពិតមែន។

«ឱ្យកាមេរ៉ាខ្ញុំមកវិញ!»

សំឡេងរបស់នាងត្រូវបានបន្លឺឡើងមកទាំងច្របូកច្របល់។ គេញាក់ស្មាសើចចំអក....នាងគិតថា នាងជាអ្នកណាបានជាដាក់បញ្ជានៅកន្លែងនេះ?

គេសម្លឹងមើលនាងហើយ នាងក៏មិនបានមើលទៅឆ្ងាយដូចគ្នា។ គ្រប់ខ្សែភ្នែករបស់ហ្សេនគឺផ្តោតលើCold។

«Cold មនុស្សនេះបងម៉ារីអូឱ្យនាំខ្លួន!» ពួកBonannoម្នាក់និយាយ។

Cold ងាកទៅជននោះ ហើយតបតស្មើធម្មតាៈ

«ប្រាប់ថា នាងនៅជាមួយខ្ញុំ! ខ្ញុំលេងពីរឬបីថ្ងៃ បន្ទាប់ពីហ្នឹង ចាំមកម្តងទៀត!»

គ្រប់គ្នានៅទីនេះ ស្ងាត់សឹងមិនហ៊ានដកដង្ហើម សូម្បីបន្ទប់ឬអាងទឹកទាំងមូល ក៏សឹងតែនៅស្ងៀមស្ងាត់ក្រោមសម្ពាធបញ្ជារបស់ Cold Cortes។

«តែ.....!»

Cold សម្លឹងនាងមួយឆ្វាច់ទៀត ហើយចាកចេញទៅទិសផ្សេងបាំងបាត់ក្នុងជណ្ដើរ ទុកឱ្យកងកម្លាំងគេពីរនាក់មកទាញយកនាងទៅតាមក្រោយ។

អ្នកផ្សេងនៃ Bonanno មិនមានទឹកមុខយល់ស្របឬព្រមតាមសំណើត្រជាក់ៗរបស់Coldទេ តែក៏មិនហ៊ានកម្រើកអ្វី។ គេរកនឹកមិនឃើញឡើយថាColdលេងអីជាមួយនាង? ខ្វះណាស់ឬស្រីស្អាតនៅញូវជេស៊ី?

«ចេញទៅ!»

សំឡេងក្រុមរបស់Coldបណ្ដេញក្រុមម៉ារីអូចេញ។ ប្រហែលជាមកដល់ទីនេះ ចួបនឹងគេ....Cold Cortes ជាជម្រើសល្អ .....មិនបាច់ស្លាប់ដូចមេផ្នែកធនាគារម្នាក់នោះ។